ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខៈ ០០៧/២៦

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ពុធ ១១ រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២៦*

## សេចក្តីជូនដំណឹង

### ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក ឈ្នះជ័យលាភីឈ្នួញជើងសាមូលបត្រឆ្នើមសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៥

ផ្សារមូលបត្រកម្ពុជា (ផមក) មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ជ័យលាភីឈ្នួញជើងសាមូលបត្រឆ្នើម សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៥ គឺបានទៅលើ ក្រុមហ៊ុនមូលបត្រ **អេស៊ីលីដា ម.ក** ។ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃមាន ដូចខាងក្រោម÷

| | |
|---|---|
| ១. ទំហំជួញដូរមូលបត្រសរុបប្រចាំត្រីមាស | ២០ ពិន្ទុ |
| ២. បម្រែបម្រួលនៃទំហំជួញដូរ | ២០ ពិន្ទុ |
| ៣. ចំនួនគណនីជួញដូរដែលបានបើកថ្មីប្រចាំត្រីមាស | ២០ ពិន្ទុ |
| ៤. បម្រែបម្រួលនៃចំនួនគណនីជួញដូរ | ២០ ពិន្ទុ |
| ៥. វង្វាយតម្លៃដោយវិនិយោគិន | ២០ ពិន្ទុ |

តាមរយៈលក្ខខណ្ឌវិនិច្ឆ័យខាងលើ ក្រុមហ៊ុនមូលបត្រ **អេស៊ីលីដា ម.ក** បានជាប់ជាជ័យលាភីក្នុងចំណោមឈ្នួញជើងសាមូលបត្រ ទាំង ១១។

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជនតាមរយៈ ក្រុមហ៊ុនមូលបត្រ **អេស៊ីលីដា ម.ក** មានចំនួន ៣៨ ពាន់លានរៀល ពោលគឺស្មើនឹង ៥៦,៩០% នៃទំហំជួញដូរមូលបត្រសរុប ហើយគណនីជួញដូរថ្មីដែលបានបើកជាមួយក្រុមហ៊ុន មានចំនួន ៣.៥៣២ គណនី។ ក្រុមហ៊ុនមូលបត្រ **អេស៊ីលីដា ម.ក** មានភាពសកម្មក្នុងការសហការជាមួយដៃគូនានាក្នុងការរៀបចំព្រឹត្តិការណ៍ដែលទទួលបានការចូលរួមពីសាធារណជនជាច្រើន ក៏ដូចជាបានផ្តល់នូវកម្មវិធីពិសេសដល់អតិថិជនថ្មី ក្នុងគោលបំណងអប់រំ ផ្សព្វផ្សាយ និងជំរុញសកម្មភាពជួញដូរមូលបត្រ។

គួររំលឹកផងដែរថា កម្មវិធីឈ្នួញជើងសាមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកនូវ ក្រុមហ៊ុនឈ្នួញជើងសាមូលបត្រឆ្នើមប្រចាំត្រីមាសនីមួយៗ ដែលមានភាពឈានមុខគេ ក្នុងការផ្តល់សេវាកម្មឈ្នួញជើងសាមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន និង មានការខិតខំប្រឹងប្រែង ក្នុងការជំរុញសកម្មភាពជួញដូរក្នុងទីផ្សារ។

ផ្សារមូលបត្រកម្ពុជា CSX Cambodia Securities Exchange

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷

នាយកដ្ឋានប្រតិបត្តិការទីផ្សារ

អ៊ីម៉ែល÷ market@csx.com.kh